# សេចក្ដីប្រកាស
# អង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិជនជាតិដើម

(អនុម័តដោយសេចក្ដីសំរេចរបស់មហាសន្និបាតលេខ ៦១/២៩៥
ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧)

*ដោយផ្អែកលើ* គោលបំណងនិងគោលការណ៍ផ្សេងៗនៃធម្មនុញ្ញសហប្រជាជាតិ និងសុឆន្ទៈក្នុងការបំពេញកាតព្វកិច្ចដោយបណ្ដារដ្ឋស្របតាមធម្មនុញ្ញនេះ

*ដោយអះអាងថា* ជនជាតិដើមមានសិទ្ធិស្មើគ្នា ដូចប្រជាជនដទៃទៀត ខណៈដែលទទួលស្គាល់ថា មនុស្សទាំងអស់មានសិទ្ធិដើម្បីមានភាពផ្សេងពីគ្នា ជនជាតិដើមអាចចាត់ទុកខ្លួនគេមានលក្ខណៈផ្សេងពីអ្នកដទៃ ហើយលក្ខណៈផ្សេងពីអ្នកដទៃនោះ ជាសិទ្ធិត្រូវតែបានទទួលការគោរព

*ដោយអះអាងដែរថា* មនុស្សទាំងអស់ចូលរួមវិភាគបង្កើតភាពចម្រុះនិងភាពសម្បូរណ៍បែបនៃអារ្យធម៌និងវប្បធម៌ដែលបង្កើតបានជាមតិករួម របស់មនុស្សជាតិ

*ដោយអះអាងបន្ថែមទៀតថា* លទ្ធិ គោលនយោបាយ និងរាល់កិច្ចអនុវត្តទាំងអស់ ផ្អែកលើ ឬលើកឧត្ដមភាពរបស់ជនជាតិ ឬបុគ្គល ដោយឈរលើមូលដ្ឋានដើមកំណើតជាតិ ឬសាសន៍ ឬសាសនា ឬភាពខុសគ្នាគ្នាខាងជាតិពិន្ទុនិងវប្បធម៌ គឺជាការប្រកាន់ពូជសាសន៍ មិនត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រ គ្មានតំលៃគតិយុត្តិ មិនអាចទទួលយកបានខាងសីលធម៌ និងជាអំពើអយុត្តិធម៌សង្គម

*ដោយអះអាងជាថ្មីថា* ជនជាតិដើម ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន គប្បីរួចផុតពីការរើសអើង ទោះជាក្នុងរូបភាពណាក៏ដោយ

*ដោយបារម្ភថា* ជនជាតិដើមបានទទួលរងនូវអំពើអយុត្តិធម៌ជាប្រវត្តិសាស្ត្រ ដែលបណ្ដាលមកពី ដូចជា ការធ្វើអាណានិគមនិយម និងការដកហូតដីធ្លី ដែនដី

និងប្រភពធនធានរបស់ពួកគេដែលរារាំងពួកគេក្នុងការប្រើប្រាស់សិទ្ធិជាពិសេស សិទ្ធិក្នុងការអភិវឌ្ឍន៍ តាមសេចក្តីត្រូវការ និងផលប្រយោជន៍របស់ខ្លួន

*ដោយទទួលស្គាល់* នូវតម្រូវការជាបន្ទាន់ឲ្យគោរព និងលើកស្ទួយសិទ្ធិមានពីកំណើតរបស់ជនជាតិដើម ដែលកើតចេញពីរចនាសម្ព័ននយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ខាងជំនឿ ប្រវត្តិសាស្រ្ត និងទស្សនៈវិជ្ជា ជាពិសេសសិទ្ធិរបស់ពួកគេលើដីធ្លី ដែនដី និងប្រភពធនធាន

*ដោយទទួលស្គាល់ផងដែរថា* តម្រូវការជាបន្ទាន់ឲ្យគោរពនិងលើកស្ទួយជនជាតិដើម ដែលមានចែងក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងការសម្រុះសម្រួលក្នុងន័យស្ថាបនាផ្សេងៗទៀត ជាមួយរដ្ឋនានា

*ដោយស្វាគមន៍* ការពិតដែលថា ជនជាតិដើមកំពុងរៀបចំខ្លួន ដើម្បីអនុវត្តន៍នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីបញ្ចប់ការរើសអើង និងការសង្កត់សង្កិនគ្រប់រូបភាពនៅពេលណាដែលកើតមាន

*ដោយជឿជាក់ថា* ការគ្រប់គ្រងរបស់ជនជាតិដើម លើការអភិវឌ្ឍន៍នានា ជះឥទ្ធិពលលើពួកគេ លើដីធ្លី ដែនដី និងប្រភពធនធានរបស់គេ និងផ្តល់លទ្ធភាពឲ្យពួកគេក្នុងការរក្សានិងពង្រឹង នូវស្ថានភាព វប្បធម៌ ប្រពៃណី នឹងលើកកំពស់ការអភិវឌ្ឍន៍ ស្របតាមបំណងប្រាថ្នានិងសេចក្តីត្រូវការរបស់ខ្លួន

*ដោយទទួលស្គាល់ដែរថា* ការគោរពចំពោះចំណេះដឹង វប្បធម៌ និងការអនុវត្តជាប្រពៃណីរបស់ជនជាតិដើមរួមចំណែកក្នុងការអនុវត្ត ប្រកបដោយនិរន្តរភាព សមធម៌ និងការគ្រប់គ្រងបរិដ្ឋានយ៉ាងត្រឹមត្រូវ

*ដោយបញ្ជាក់យ៉ាងច្បាស់ពី* ការរួមចំណែកដល់ការមិនឲ្យមានវត្តមានយោធា នៅលើដីធ្លី និងដែនដីរបស់ជនជាតិដើម ដើម្បីនាំមកនូវសន្តិភាព ការអភិវឌ្ឍ និងការរីកចំរើនខាងសេដ្ឋកិច្ច សង្គមកិច្ច ការយោគយល់គ្នា និងទំនាក់ទំនងជាមួយប្រជាជាតិនិងប្រជាពលរដ្ឋលើពិភពលោក

*ដោយទទួលស្គាល់ជាពិសេស* នូវសិទ្ធិនៃក្រុមគ្រួសារ និងសហាគមន៍ជនជាតិដើម ក្នុងការបន្តទទួលខុសត្រូវរួម ចំពោះការចិញ្ចឹមបីបាច់រក្សា ការបណ្តុះបណ្តាល ការអប់រំ និងសុខុមាលភាពកូនចៅរបស់ពួកគេ មានលក្ខណស្របគ្នា

នឹងសិទ្ធិកុមារ

*ដោយចាត់ទុកថា* សិទ្ធិទាំងឡាយដែលមានចែងក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀត រវាងរដ្ឋនានានិងជនជាតិដើមដែលនៅក្នុងស្ថានភាពខ្លះ ជាកង្វល់ ជាផលប្រយោជន៍ ការទទួលខុសត្រូវ និងមានចរិតអន្តរជាតិ

*ដោយចាត់ទុកដែរថា* សន្ធិសញ្ញា កិច្ចព្រមព្រៀម និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀត និងជំហរដែលទាក់ទងរឿងទាំងអស់នេះ គឺជាមូលដ្ឋាននៃការពង្រឹងភាពជាដៃគូ រវាងជនជាតិដើម និងរដ្ឋនានា

*ដោយទទួលស្គាល់ថា* ធម្មនុញ្ញសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌[2] កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ ពលរដ្ឋនិងសិទ្ធិនយោបាយ ព្រមទាំងសេចក្តីប្រកាស និងកម្មវិធីសកម្មភាព[3] ទីក្រុងវីយ៉ែនបញ្ជាក់ពីសារៈសំខាននៃសិទ្ធិស្វ័យសម្រេចរបស់មនុស្សគ្រប់រូប ក្នុងស្មារតីនេះមនុស្សទាំងអស់អាចសម្រេចចិត្តដោយសេរី អំពីឋានៈ នយោបាយរបស់ខ្លួននិងធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី

*ដោយចងចាំក្នុងចិត្តថា* មិនមានចំណុចណាមួយក្នុងសេចក្តីប្រកាសនេះអាចត្រូវបានប្រើប្រាស ដើម្បីបដិសេធបុគ្គលណាម្នាក់ នូវសិទ្ធិស្វ័យសំរេចដែលបានអនុវត្តស្របតាមច្បាប់អន្តរជាតិឡើយ

*ដោយជឿជាក់ថា* ការទទួលស្គាល់សិទ្ធិជនជាតិដើមក្នុងសេចក្តីប្រកាសនេះនឹងលើកកំពស់ទំនាក់ទំនងប្រកបដោយសុខដុម និងដោយសហការគ្នា រវាងរដ្ឋនិងជនជាតិដើម ដោយផ្អែកលើគោលការយុត្តិធម៌ ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការមិនរើសអើង និងភាពសុចរិត

*ដោយលើកទឹកចិត្ត* រដ្ឋទាំងអស់ឲ្យគោរពនិងអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ដូចដែលអនុវត្តចំពោះជនជាតិដើម តាមលិខិតុបករណ៍អន្តរជាតិ ជាពិសេសលិខិតុករណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សដោយមានការពិគ្រោះយោបល់និងសហការគ្នា ជាមួយបុគ្គលដែលពាក់ព័ន្ធ

[2] See resolution 2200 A (XXI), annex
[3] A/CONF.157/24 (Part I), chap. III

*ដោយបញ្ជាក់ថា* អង្គការសហប្រជាជាតិ មានតួនាទីសំខាន់ដែលត្រូវបន្តអនុវត្ត ក្នុងការលើកកំពស់និងកិច្ចការពារសិទ្ធិជនជាតិដើម

*ដោយជឿថា* សេចក្តីប្រកាសនេះ គឺជាការបោះជំហានទៅមុខដ៏សំខាន់មួយក្នុងកិច្ចទទួលស្គាល់ការលើកស្ទួយ កិច្ចការពារសិទ្ធិសេរីភាពជនជាតិដើម និងក្នុងការបង្កើតសកម្មភាពពាក់ព័ន្ធ នៃប្រព័ន្ធអង្គការសហប្រជាជាតិក្នុងវិស័យនេះ

*ដោយទទួលស្គាល់និងអះអាងជាថ្មីថា* រាល់បុគ្គលជនជាតិដើម ដោយគ្មានការរើសអើង មានសិទ្ធិទទួលនូវសិទ្ធិមនុស្សទាំងអស់ ដែលចែងដោយច្បាប់អន្តរជាតិ ហើយជនជាតិដើមនោះ មានប្រចាំខ្លួននូវសិទ្ធិសមូហភាព ដែលជាការចាំបាច់សម្រាប់រស់នៅ សុខុមាលភាព និងការអភិវឌ្ឍន៍ទាំងស្រុងក្នុងឋានៈជាមនុស្ស

*ដោយទទួលស្គាល់ផងដែរថា* ជនជាតិដើមមានស្ថានភាពខុសគ្នាពីភូមិភាគមួយ ទៅភូមិភាគមួយ ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ *និងថា*សារៈសំខាន់នៃលក្ខណៈពិសេសនៃជាតិសាសន៍ តំបន់ សាវតាប្រវត្តិសាស្ត្រ និងវប្បធម៌ផ្សេងៗគប្បីត្រូវបានយកមកពិចារណា

*សូមប្រកាសជាមហោឡារិក* នូវ**សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម** ខាងក្រោមនេះ ជាបទដ្ឋាននៃសមិទ្ធិផល ដែលត្រូវបន្តអនុវត្ត តាមស្មារតីនៃភាពជាដៃគូ និងការគោរពគ្នាទៅវិញទៅមក។

*មាត្រា១*

ជនជាតិដើម ជាសមូហភាព ឬជាបុគ្គលមានសិទ្ធិ ទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ដែលបានទទួលស្គាល់ដោយធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានា។

*មាត្រា២*

ជនជាតិដើម និងបុគ្គលជនជាតិដើម មានសេរីភាព និងសមភាពដូចប្រជាពលរដ្ឋ និងបុគ្គលដទៃទៀត ព្រមទាំងមានសិទ្ធិរួចផុតពីការរើសអើងគ្រប់រូបភាព ក្នុងការអនុវត្តសិទ្ធិជាពិសេសដោយផ្អែកលើមូលដ្ឋាននៃដើមកំណើតឬអត្តសញ្ញាណរបស់ខ្លួន ជាជនជាតិដើម។

*មាត្រា៣*

ជនជាតិដើម មានសិទ្ធិស្វ័យសម្រេច។ តាមស្មារតីនៃសិទ្ធិនេះ ជនជាតិដើមធ្វើសេចក្តីសម្រេចចិត្ត អំពីស្ថានភាពនយោបាយរបស់ខ្លួនដោយសេរី និងធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ខ្លួនដោយសេរី។

*មាត្រា៤*

ជនជាតិដើម ក្នុងការអនុវត្តសិទ្ធិស្វ័យសម្រេចរបស់ខ្លួន មានសិទ្ធិគ្រប់គ្រងដោយខ្លួនឯងឬដោយស្វ័យភាពលើបញ្ហាទាំងឡាយដែលទាក់ទងដល់កិច្ចការផ្ទៃក្នុង និងកិច្ចការនៅមូលដ្ឋានរបស់ខ្លួន ព្រមទាំងវិធីសាស្ត្រនិងមធ្យោបាយផ្សេងៗ សម្រាប់ផ្តល់ហិរញ្ញវត្ថុ ដល់ដំណើរការស្វ័យភាពរបស់ខ្លួន។

*មាត្រា៥*

ជនជាតិដើម មានសិទ្ធិរក្សា និងពង្រឹងស្ថាប័ននយោបាយ ច្បាប់ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដោយលែករបស់ខ្លួន ដែលទន្ទឹមនេះក៏មានសិទ្ធិចូលរួមយ៉ាងពេញលេញ ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់រដ្ឋផងដែរ តាមការជ្រើសរើសរបស់ពួកគេ។

*មាត្រា៦*

ជនជាតិដើមគ្រប់រូប មានសិទ្ធិទទួលសញ្ជាតិ។

*មាត្រា៧*

១/ជនជាតិដើម មានសិទ្ធិរស់រានមានជីវិត បូរណភាពរូបកាយ និងបញ្ញាស្មារតី មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

២/ជនជាតិដើម មានសិទ្ធិសមូហភាពក្នុងការរស់នៅប្រកបដោយសេរីភាព សន្តិភាព និងសន្តិសុខ ជាពលរដ្ឋមានលក្ខណៈផ្សេងៗពីគេ ហើយនិង មិនត្រូវជាកម្មវត្ថុ នៃអំពើប្រល័យពូជសាសន៍ ឬអំពើហិង្សាណាមួយឡើយ រួមទាំងការបំបែកកុមារដោយបង្ខំ ចេញពីក្រុមមួយ ទៅដាក់ក្រុមផ្សេងមួយទៀត។

*មាត្រា៨*

១/ជនជាតិដើម និងបុគ្គលជាជនជាតិដើម មានសិទ្ធិមិនស្ថិតនៅក្នុងកម្មវត្ថុនៃការបង្ខំឲ្យរស់នៅលាយឡំក្នុងសហគមន៍ផ្សេង ឬការបំផ្លាញវប្បធម៌របស់ខ្លួនឡើយ។

២/រដ្ឋទាំងឡាយត្រូវផ្តល់យន្តការការពារ និងដោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះ ៖

ក/អំពើណាមួយដែលមានបំណង ឬឥទ្ធិពលដល់ការដកហូតពីពួកគេនូវបូរណភាពជាប្រជាពលរដ្ឋមានលក្ខណៈផ្សេងពីគេ ឬដកហូតតំលៃវប្បធម៌ ឬអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេ។

ខ/អំពើណាមួយដែលមានបំណង ឬឥទ្ធិពលដល់ការដកហូតពីពួកគេនូវដីធ្លី ដែនដី ឬប្រភពធនធានរបស់ពួកគេ។

គ/រូបភាពណាមួយ នៃការជម្លៀសជនជាតិដើមដោយបង្ខំ ដែលមានគោលបំណងឬមានឥទ្ធិពលដល់ការរំលោភ ឬការធ្វើឲ្យអន្តរាយដល់សិទ្ធិរបស់ពួកគេ។

ឃ/រូបភាពណាមួយនៃការបង្ខំ ឲ្យរស់នៅលាយឡំក្នុងសហគមន៍ផ្សេង ឬសមាហរណកម្ម។

ង/រូបភាពណាមួយនៃការឃោសនា ដែលបានរៀបចំឡើង ដើម្បីជំរុញ ឬញុះញង់ឲ្យមានការរើសអើងជាតិសាសន៍ ឬជាតិពន្ធុ សំដៅប្រឆាំងជន

ជាតិដើម។

*មាត្រា៩*

ជនជាតិដើម និងបុគ្គលជាជនជាតិដើម មានសិទ្ធិស្ថិតនៅជាសមាជិកសហាគមន៍ ជនជាតិដើម ឬសង្គមជាតិសមស្របតាមប្រពៃណី និងទំនៀមទម្លាប់របស់សហាគមន៍ និងសង្គមជាតិពាក់ព័ន្ធ។ គ្មានការរើសអើងណាមួយ កើតឡើងដោយសារការប្រើសិទ្ធិនេះឡើយ។

*មាត្រា១០*

ជនជាតិដើម មិនត្រូវបានគេបណ្តេញដោយបង្ខំចេញពីដីធ្លី ឬដែនដីរបស់ខ្លួនឡើយ។ ការតាំងលំនៅថ្មី មិនត្រូវធ្វើដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឲ្យដឹងជាមុន ដល់ជនជាតិដើមដែលពាក់ព័ន្ធ និងបន្ទាប់ពីមានការព្រមព្រៀងលើសំណងត្រឹមត្រូវ និងយុត្តិធម៌នោះឡើយ ហើយបើធ្វើទៅបានត្រូវដាក់ឲ្យមាននូវជំរើសនៃការវិលត្រឡប់មកកាន់ដីធ្លី ឬដែនដីរបស់ខ្លួនវិញ។

*មាត្រា១១*

១/ជនជាតិដើម មានសិទ្ធិប្រតិបត្តិ និងធ្វើឲ្យរស់ឡើងវិញ នូវប្រពៃណីទំនៀមទម្លាប់ជាវប្បធម៌របស់ខ្លួន។ សិទ្ធិនេះ រួមមានទាំងសិទ្ធិក្នុងការថែរក្សាការពារ និងអភិវឌ្ឍន៍អ្វីដែលបង្ហាញអំពីអត្តសញ្ញាណ វប្បធម៌របស់ខ្លួន ដែលមានពីអតីតកាល បច្ចុប្បន្ន និងអនាគត ដូចជាតំបន់បុរាណវិទ្យា និងស្ថានីយប្រវត្តិសាស្ត្រ បុរាណវត្ថុ រចនាបថ ពិធីបុណ្យ បច្ចេកវិទ្យា និងសិល្បៈទស្សនីយភាព និងការសំដែងសិល្បៈ និងអក្សរសាស្ត្រ។

២/រដ្ឋទាំងឡាយ ត្រូវផ្តល់ឲ្យមានដំណោះស្រាយតាមរយៈយន្តការ មានប្រសិទ្ធិភាព ដែលរួមទាំងបដិទាន ដោយបានរៀបចំបង្កើតឡើងជាមួយជនជាតិដើម ចំពោះកម្មសិទ្ធិវប្បធម៌ កម្មសិទ្ធិបញ្ញា កម្មសិទ្ធិសាសនា កម្មសិទ្ធិជំនឿរបស់ពួកគេ ដែលត្រូវដកហូតដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់

ឲ្យដឹងជាមុន ឬដែលរំលោភលើច្បាប់ ប្រពៃណី និងទំនៀមទម្លាប់របស់ពួកគេ។

*មាត្រា១២*

១/ជនជាតិដើម មានសិទ្ធិបង្ហាញ ប្រតិបត្តិ អភិវឌ្ឍន៍ និងបង្រៀន ប្រពៃណីខាងជំនឿនិងសាសនារបស់ខ្លួន ទំនៀមទម្លាប់និងពិធីបុណ្យផ្សេងៗ ហើយមានសិទ្ធិរក្សាការពារ និងសិទ្ធិជាឯកជនក្នុងការប្រើប្រាស់ទីកន្លែងសាសនា និងវប្បធម៌របស់ខ្លួន។ មានសិទ្ធិប្រើប្រាស់និងគ្រប់គ្រងវត្ថុសម្រាប់បុណ្យនានា និងមានសិទ្ធិនាំអដ្ឋិធាតុត្រឡប់មកកាន់ដែនដីកំណើតរបស់ពួកគេ។

២/រដ្ឋនានា ត្រូវផ្តល់លក្ខណៈងាយស្រួល ដល់ការទទួលយកមកប្រើប្រាស់ និង/ឬ នាំត្រឡប់មកកាន់ដែនដីកំណើតវិញ នូវវត្ថុសម្រាប់ពិធីបុណ្យ និងអដ្ឋិធាតុ ដែលជាភោគទ្រព្យរបស់ពួកគេ តាមរយៈយន្តការយុត្តិធម៌ តម្លាភាព និងប្រសិទ្ធិ-ភាព ដែលយន្តការនេះបានបង្កើតឡើងរួមគ្នាជាមួយជនជាតិដើមពាក់ព័ន្ធ។

*មាត្រា១៣*

១/ជនជាតិដើម មានសិទ្ធិធ្វើឲ្យរស់រវើកឡើងវិញ ប្រើប្រាស់ អភិវឌ្ឍន៍ និងផ្ទេរឲ្យកូនចៅជំនាន់ក្រោយ នូវប្រវត្តិសាស្ត្រ ភាសា ច្បាប់ទម្លាប់ ទស្សនវិជ្ជា ប្រព័ន្ធនៃការសរសេរ និងអក្សរសាស្ត្រ ព្រមទាំងធ្វើការកំណត់ឈ្មោះ និងរក្សាឈ្មោះគេដោយខ្លួនឯង សម្រាប់សហគមន៍ ទីកន្លែង និងបុគ្គល។

២/រដ្ឋនានា ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាថាសិទ្ធិទាំងនោះ ត្រូវបានការពារនិងធានាផងដែរថា ជនជាតិដើមអាចយល់ដឹង និងត្រូវធ្វើឲ្យបានយល់ដឹង អំពីដំណើរការនយោបាយ ច្បាប់ និងរដ្ឋបាល ហើយប្រសិនជាចាំបាច់ត្រូវធ្វើឡើងតាមរយៈការពន្យល់បកស្រាយ ឬតាមមធ្យោយសមស្រប ដ៏ទៃទៀត។

*មាត្រា១៤*

១/ជនជាតិដើម មានសិទ្ធិបង្កើតនិងគ្រប់គ្រងស្ថាប័ន និងប្រព័ន្ធអប់រំរបស់

ខ្លួន ដោយផ្តល់ការអប់រំជាភាសារបស់ខ្លួនផ្ទាល់ ក្នុងលក្ខណៈសមស្របនឹងវិធីសាស្ត្រ តាមវប្បធម៌និងការបង្រៀន និងការរៀនសូត្ររបស់ពួកគេ។

២/បុគ្គលជាជនជាតិដើមគ្រប់រូប ជាពិសេសកុមារ មានសិទ្ធិទទួលបានការអប់រំនៅគ្រប់កំរិតនិងគ្រប់រូបភាពនៃការអប់រំរបស់រដ្ឋ ដោយគ្មានការរើសអើងឡើយ។

៣/រដ្ឋទាំងឡាយ ដោយសហការជាមួយនឹងជនជាតិដើម ត្រូវចាត់វិធានការ ប្រកបដោយប្រសិទ្ធិភាព ដើម្បីឲ្យបុគ្គលជនជាតិដើម ជាពិសេសកុមាររួមទាំងអ្នកដែលរស់នៅក្រៅសហគមន៍ផង មានសិទ្ធិទទួលបាន ការអប់រំទៅតាមវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគេ និងត្រូវផ្តល់ការអប់រំនោះ ជាភាសារបស់ពួកគេនៅពេលណាដែលអាចធ្វើបាន។

*មាត្រា១៥*

១/ជនជាតិដើម មានសិទ្ធិចំពោះភាពថ្លៃថ្នូរ និងភាពចំរុះនៃវប្បធម៌ ប្រពៃណី និងបំណងប្រាថ្នា ដែលត្រូវឆ្លុះបញ្ចាំងយ៉ាងសមស្រប នៅក្នុងការអប់រំ និងពត៌មានសាធារណៈ។

២/រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដោយការពិគ្រោះយោបល់ និងសហការជាមួយជនជាតិដើមពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងលប់បំបាត់ការរើសអើង ព្រមទាំងលើកកំពស់ការអធ្យាស្រ័យគ្នា ការយោគយល់គ្នា និងទំនាក់ទំនងល្អក្នុងចំណោមជនជាតិដើម និងនៅគ្រប់ផ្នែកនៃសង្គម។

*មាត្រា១៦*

១/ជនជាតិដើម មានសិទ្ធិបង្កើតប្រព័ន្ធផ្សព្វផ្សាយ ដោយប្រើភាសារបស់ខ្លួន និងមានសិទ្ធិប្រើប្រាស់តាមគ្រប់រូបភាពនូវប្រព័ន្ធផ្សព្វផ្សាយដែលមិនមែនជារបស់ជនជាតិដើម ដោយគ្មានការរើសអើងឡើយ។

២/រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាថាប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋពិតជាឆ្លុះបញ្ចាំងនូវភាពចំរុះនៃវប្បធម៌របស់ជនជាតិ

ដើម។ ដោយគ្មានបុរេវិនិច្ឆ័យក្នុងការធានាសេរីភាពបញ្ចេញមតិយ៉ាងពេញលេញ រដ្ឋគប្បីលើកទឹកចិត្តឲ្យមានប្រព័ន្ធផ្សព្វផ្សាយឯកជនដើម្បីធានាដល់សេរីភាពយ៉ាងពេញលេញក្នុងការសំដែងមតិ ដែលឆ្លុះបញ្ចាំងគ្រប់គ្រាន់ អំពីភាពចំរុះនៃវប្បធម៌ជនជាតិដើម។

*មាត្រា១៧*

១/ជនជាតិដើម និងបុគ្គលជាជនជាតិដើមគ្រប់រូប មានសិទ្ធិទទួលបានយ៉ាងពេញលេញនូវសិទ្ធិគ្រប់យ៉ាង ដែលមានចែងក្នុងច្បាប់ការងារអន្តរជាតិ និងច្បាប់ការងារជាតិជាធរមាន។

២/រដ្ឋទាំងឡាយ ក្នុងការពិគ្រោះយោបល់និងសហការជាមួយជនជាតិដើម ត្រូវចាត់វិធានការជាក់ស្តែង ដើម្បីការពារកុមារជនជាតិដើម ពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬដែលអាចប៉ះពាល់ដល់ការសិក្សារបស់កុមារ ឬដែលអាចមានគ្រោះថ្នាក់ដល់សុខភាពឬការអភិវឌ្ឍន៍ខាងរាងកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គម ដោយគិតទៅដល់ភាពងាយរងគ្រោះពិសេសរបស់កុមារ និងអំពីសារៈសំខាន់នៃការអប់រំ ដើម្បីពង្រឹងសមត្ថភាពពួកគេ។

៣/បុគ្គលជាជនជាតិដើមគ្រប់រូប មានសិទ្ធិមិនស្ថិតក្រោមលក្ខខ័ណ្ឌនៃការរើសអើងណាមួយ នៃពលកម្ម ដូចជាការងារ ឬប្រាក់បៀវត្សរ៍ជាដើម។

*មាត្រា១៨*

ជនជាតិដើម មានសិទ្ធិចូលរួមធ្វើការងារសម្រេចចិត្ត លើរាល់បញ្ហាដែលអាចប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ តាមរយៈតំណាងដែលជ្រើសតាំង ដោយពួកគេផ្ទាល់ ស្របតាមនីតិវិធីរបស់ពួកគេ ក៏ដូចជាមានសិទ្ធិរក្សា និងបង្កើតស្ថាប័នជនជាតិដើម ដែលមានតួនាទីធ្វើសេចក្តីសម្រេចចិត្តនានា។

*មាត្រា១៩*

រដ្ឋទាំងឡាយ ត្រូវពិគ្រោះយោបល់និងសហការដោយសុចរិត ជាមួយជនជាតិពាក់ព័ន្ធ តាមរយៈស្ថាប័នតំណាងរបស់ខ្លួន ដើម្បីទទួលការយល់ព្រម

ដោយសេរី និងដោយបានប្រាប់ឲ្យដឹងជាមុនសិន មុននឹងអនុម័តនិងអនុវត្តវិធានការច្បាប់ ឬវិធានការរដ្ឋបាល ដែលអាចប៉ះពាល់ដល់ជនជាតិដើម។

*មាត្រា២០*

១/ជនជាតិដើម មានសិទ្ធិរក្សានិងបង្កើតស្ថាប័ននយោបាយ សេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីធានាបាននូវធម្យោបាយដើម្បីចិញ្ចឹមជីវិតនិងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងដើម្បីចូលរួមដោយសេរី នូវសកម្មភាពជាប្រពៃណី និងសេដ្ឋកិច្ចផ្សេងៗទៀត។

២/ជនជាតិដើម ដែលត្រូវគេដកហូតមធ្យោបាយក្នុងការចិញ្ចឹមជីវិតនិងការអភិវឌ្ឍន៍ មានសិទ្ធិទទួលបាននូវដំណោះស្រាយត្រឹមត្រូវនិងយុត្តិធម៌។

*មាត្រា២១*

១/ជនជាតិដើម ដោយគ្មានការរើសអើង មានសិទ្ធិក្នុងការលើកកំពស់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ច រួមមានសិទ្ធិក្នុងវិស័យអប់រំ ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងការបង្ហាត់បង្រៀនឡើងវិញលំនៅឋានអនាម័យ សុខាភិបាល និងសន្តិសុខសង្គ្រោះ ជាដើម។

២/រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ហើយបើអាចធ្វើទៅបាន ចាត់វិធានការពិសេស ដើម្បីធានាដល់ការបន្តលើកកំពស់លក្ខខណ្ឌសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ជនជាតិដើម។ រដ្ឋត្រូវយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិរបស់ជនជាតិដើម ដែលជាមនុស្សចាស់ ស្ត្រី យុវជន កុមារ និងជនពិការ។

*មាត្រា២២*

១/ក្នុងការអនុវត្តសេចក្តីប្រកាសនេះ រដ្ឋត្រូវយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិនិងសេចក្តីត្រូវការពិសេសរបស់ជនជាតិដើម ដែលជាមនុស្សចាស់ ស្ត្រី យុវជន កុមារ និងជនពិការ។

២/រដ្ឋទាំងឡាយ ត្រូវចាត់វិធានការដោយសហការជាមួយជនជាតិដើម

ដើម្បីធានាថាស្ត្រី និងកុមារនជាតិដើមទទួលបានការការពារនិងកាធានាបានទាំងស្រុងប្រឆាំងនឹងអំពើហឹង្សា និងការរើសអើងគ្រប់រូបភាព។

*មាត្រា២៣*

ជនជាតិដើម មានសិទ្ធិសម្រេចផែនការអាទិភាព និងយុត្តិសាស្ត្រនានាសម្រាប់អនុវត្តសិទ្ធិរបស់ខ្លួនចំពោះការអភិវឌ្ឍន៍។ ជាពិសេសជនជាតិដើម មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ និងសម្រេចលើកម្មវិធីសុខភាព លំនៅឋាន និងកម្មវិធីសេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងៗទៀត ដែលប៉ះពាល់ដល់ពួកគេ ហើយប្រសិនជាអាចធ្វើបាន ត្រូវគ្រប់គ្រងកម្មវិធីបែបនោះ តាមរយៈស្ថាប័នផ្ទាល់របស់ពួកគេ។

*មាត្រា២៤*

១/ជនជាតិដើម មានសិទ្ធិក្នុងការប្រើប្រាស់ឱសថបុរាណរបស់ខ្លួន និងមានសិទ្ធិរក្សាវិធីប្រតិបត្តិផ្នែកសុខភាព រួមទាំងការអភិរក្សរុក្ខជាតិ សត្វ និង រ៉ែ ដែលចាំបាច់សម្រាប់ធ្វើឱសថ។ ជនជាតិដើមគ្រប់រូប ក៏មានសិទ្ធិទទួលបាននូវសេវាកម្មសង្គមកិច្ច និងសុខាភិបាលគ្រប់យ៉ាង ដោយគ្មានការរើស អើងឡើយ។

២/ជនជាតិដើមគ្រប់រូប មានសិទ្ធិស្មើគ្នា ចំពោះបទដ្ឋានសុខភាពខាងរាងកាយនិងផ្លូវចិត្ត ដោយមានកំរិតខ្ពស់បំផុត។ រដ្ឋត្រូវចាត់វិធានការចាំបាច់ក្នុងគោលបំណងធ្វើឲ្យសម្រេចបានយ៉ាងរីកចំរើន ដល់ការទទួលបានយ៉ាងពេញលេញ នូវសិទ្ធិទាំងនោះ។

*មាត្រា២៥*

ជនជាតិដើម មានសិទ្ធិរក្សានិងពង្រឹងទំនាក់ទំនងខាងជំនឿសាសនា របស់ពួកគេ ជាមួយនឹងដីធ្លី ដែនដី ដែនទឹក និងឆ្នេរសមុទ្រ និងប្រភពធនធានផ្សេងៗទៀត ដែលពួកគេមានឬបានកាន់កាប់ និងបានប្រើប្រាស់ជាប្រពៃណី និងដើម្បីលើកកំពស់ការទទួលខុសត្រូវរបស់ពួកគេ ចំពោះកូនចៅជំនាន់ក្រោយ។

*មាត្រា២៦*

១/ជនជាតិដើម មានសិទ្ធិប្រើដីធ្លី ដែនដី និងប្រភពធនធានដែលពួកគេមាន ឬកាន់កាប់ ឬបានប្រើប្រាស់ ឬបានទទួលជាប្រពៃណី។

២/ជនជាតិដើម មានសិទ្ធជាម្ចាស់ ប្រើប្រាស់ អភិវឌ្ឍន៍ និងគ្រប់គ្រងដីធ្លី ដែនដី និងប្រភពធនធានដែលពួកគេមាន ដោយសារហេតុផលនៃកម្មសិទ្ធិជាប្រពៃណី ឬកាន់កាប់ ឬការប្រើប្រាស់ជាប្រពៃណីដទៃទៀត ក៏ដូចជាអ្វីផ្សេងទៀត ដែលពួកគេមានពីមុនមក។

៣/រដ្ឋត្រូវទទួលស្គាល់ និងការពារតាមផ្លូវច្បាប់ ចំពោះដីធ្លី ដែនដី និងប្រភពធនធាននានា។ ការទទួលស្គាល់បែបនេះ ត្រូវប្រព្រឹត្តទៅដោយគោរពយ៉ាងត្រឹមត្រូវ ចំពោះទំនៀមទម្លាប់ ប្រពៃណី និងប្រព័ន្ធកាន់កាប់ដីធ្លីរបស់ជនជាតិដើមពាក់ព័ន្ធ។

*មាត្រា២៧*

រដ្ឋទាំងឡាយ ដោយសហការជាមួយជនជាតិពាក់ព័ន្ធ ត្រូវបង្កើតនិងអនុវត្តកិច្ចដំណើរការប្រកបដោយភាពយុត្តិធម៌ ឯករាជ្យ មិនលំអៀង ដោយចំហ និងតម្លាភាព ដោយទទួលស្គាល់យ៉ាងត្រឹមត្រូវចំពោះច្បាប់ ប្រពៃណី ទំនៀមទម្លាប់ និងប្រព័ន្ធកាន់កាប់ដីធ្លីរបស់ជនជាតិដើម ទទួលស្គាល់និងវិនិច្ឆ័យសិទ្ធិរបស់ជនជាតិដើម ដែលទាក់ទងនឹងដីធ្លី ទឹកដី និងប្រភពធនធាននានា រួមទាំងអ្វីៗដែលពួកគេមាន ឬបានកាន់កាប់ ឬបានប្រើប្រាស់ជាប្រពៃណី។ ជនជាតិដើម ត្រូវមានសិទ្ធិចូលរួមក្នុងកិច្ចការនេះ។

*មាត្រា២៨*

១/ជនជាតិដើម មានសិទ្ធិទទួលបានដំណោះស្រាយតាមមធ្យោបាយផ្សេងៗ ដែលរួមទាំងការធ្វើដូចដើមវិញ ឬប្រសិនបើករណីនេះមិនអាចធ្វើទៅបាន ត្រូវផ្តល់សំណងត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព សម្រាប់ដីធ្លី ទឹកដី និង ប្រភពធនធាននានា ដែលជនជាតិដើមមាន ឬបានកាន់កាប់ ឬបានប្រើប្រាស់ ជាប្រពៃណី ហើយដែល

ត្រូវបានដកហូតយក បានកាន់កាប់ បានប្រើប្រាស់ ឬបានធ្វើឲ្យអន្តរាយដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឲ្យដឹងជាមុន ដល់ជនជាតិដើមពាក់ព័ន្ធ។

២/លុះត្រាតែមានការយល់ព្រមជាមុនដោយសេរីពីជនជាតិដើមពាក់ពន្ធ បើមិនដូច្នោះទេ សំណងត្រូវធ្វើឡើងក្នុងរូបភាពដីធ្លី និងធនធានដែលមានតំលៃស្មើនឹងគុណភាព ទំហំ ឋានៈផ្លូវច្បាប់ ឬសំណងជាប្រាក់ ឬដំណោះស្រាយសមរម្យផ្សេងទៀត។

*មាត្រា២៩*

១/ជនជាតិដើម មានសិទ្ធិក្នុងការអភិរក្ស និងកិច្ចការពារបរិស្ថាន និងសមត្ថភាពផលិតកម្ម លើដីធ្លី ដែនដី និងប្រភពធនធានរបស់ពួកគេ។ រដ្ឋត្រូវបង្កើតនិងអនុវត្តកម្មវិធីជំនួយ សម្រាប់ជនជាតិដើម ក្នុងការអភិរក្ស និងការការពារបែបនេះ ដោយគ្មានការរើសអើងឡើយ។

២/រដ្ឋទាំងឡាយ ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាមិនឲ្យមានឃ្លាំងដាក់សម្ភារៈដែលបង្កគ្រោះថ្នាក់ ឬបោះចោលសម្ភារៈបែបនេះនៅលើដីធ្លី ដែនដីរបស់ជនជាតិដើម ដោយគ្មានការយល់ព្រមដោយសេរី ឬដោយស្មគ្រចិត្តជាមុន ពីជនជាតិដើមពាក់ព័ន្ធ។

៣/រដ្ឋទាំងឡាយ ក៏ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាពតាមការចាំបាច់ ដើម្បីធានាថា កម្មវិធីពិនិត្យ តាមដាន ថែរក្សា និងព្យាបាលសុខភាពជនជាតិដើម ដែលបានបង្កើតនិងអនុវត្តដោយជនជាតិដើម ដែលរងផលប៉ះ ពាល់ដោយសារសម្ភារៈបែបនេះ ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

*មាត្រា៣០*

១/សកម្មភាពយោធា មិនត្រូវឲ្យមានអនុវត្តនៅលើដីធ្លី ឬដែនដី របស់ជនជាតិដើមឡើយ ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថា មានការគម្រាមគំហែងយ៉ាងធ្ងន់ធ្ងដល់ផលប្រយោជន៍សាធារណៈពាក់ព័ន្ធទេ ឬប្រសិនជាគ្មានការយល់

ព្រមដោយសេរី ឬតាមការស្នើសុំពីជនជាតិដើមពាក់ព័ន្ធទេនោះ។

២/រដ្ឋទាំងឡាយ ត្រូវធ្វើការពិគ្រោះយោបល់ប្រកបដោយប្រសិទ្ធិភាព ជាមួយជនជាតិដើមពាក់ព័ន្ធតាមរយៈនីតិវិធីសមស្រប ហើយជាពិសេសតាមរយៈ ស្ថាប័នតំណាងរបស់ពួកគេ មុននឹងប្រើប្រាស់ដីធ្លី ឬដែនដីរបស់ពួកគេ សម្រាប់ សកម្មភាពយោធា។

*មាត្រា ៣១*

១/ជនជាតិដើម មានសិទ្ធិរក្សា គ្រប់គ្រង ការពារ និងអភិវឌ្ឍន៍មត៌ក វប្បធម៌ ចំណេះដឹង និងប្រពៃណី និងការសំដែងនូវវប្បធម៌ ប្រពៃណី ក៏ដូចជា ការបង្ហាញឲ្យដឹង អំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវប្បធម៌របស់ពួកគេ រួមទាំង ធនធានមនុស្សនិងធនធានពិន្ទុ គ្រាប់ពូជ ឱសថ ចំណេះដឹងខាងរុក្ខជាតិ និងសត្វព្រៃ ប្រពៃណីនិយាយផ្ទាល់មាត់ អក្សរសាស្ត្រ រចនាបថ កីឡា និង ល្បែងប្រពៃណី ព្រមទាំងសិល្បៈសំដែង និងទស្សនីយភាព។ ជនជាតិដើម មានសិទ្ធិរក្សាគ្រប់គ្រង ការពារ និងបង្កើតឡើង នូវកម្មសិទ្ធិបញ្ញារបស់ខ្លួន លើមរតិកវប្បធម៌ ចំណេះដឹងជាប្រពៃណី និងការសំដែងវប្បធម៌ប្រពៃណី។

២/ដោយសហការជាមួយជនជាតិដើម រដ្ឋទាំងឡាយ ត្រូវចាត់វិធានការ ប្រកបដោយប្រសិទ្ធិភាព ដើម្បីទទួលស្គាល់ និងការពារដល់ការអនុវត្តសិទ្ធិទាំង នេះ។

*មាត្រា ៣២*

១/ជនជាតិដើម មានសិទ្ធិសម្រេច និងបង្កើតផែនការអាទិទេពនិងយុទ្ធ-សាស្ត្រ នានាសម្រាប់ការអភិវឌ្ឍន៍ ឬការប្រើប្រាស់ដីធ្លី ឬដែនដី និងប្រភពធនធាន ផ្សេងទៀតរបស់ពួកគេ។

២/រដ្ឋទាំងឡាយ ត្រូវពិគ្រោះយោបល់ និងសហការដោយសុចរិត ជាមួយជនជាតិដើមពាក់ព័ន្ធ តាមរយៈស្ថាប័នតំណាងរបស់ខ្លួនផ្ទាល់ ដើម្បីទទួល ការយល់ព្រមដោយសេរី និងដោយបានប្រាប់ឲ្យដឹងមុន មុននឹងអនុម័តលើគំរោង

ណាមួយ ដែលប៉ះពាល់ដល់ដីធ្លី ឬដែនដីនិងធនធាននានារបស់ពួកគេ ជាពិសេស គំរោងទាំងឡាយដែលទាក់ទងនឹងការអភិវឌ្ឍន៍ ការប្រើប្រាស់ និងការរុករករ៉ែក្នុងដី ក្នុងដែនទឹក ឬប្រភពធនធានផ្សេងៗទៀត។

៣/រដ្ឋទាំងឡាយ ត្រូវផ្តល់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីជួសជុលការខូចខាត ឲ្យបានត្រឹមត្រូវនិងយុត្តិធម៌ សម្រាប់សកម្មភាពទាំងនេះ និងត្រូវចាត់វិធានការសមស្រប ដើម្បីបន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ ដល់បរិស្ថានសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ ឬស្មារតី។

*មាត្រា៣៣*

១/ជនជាតិដើម មានសិទ្ធិក្នុងការកំណត់អត្តសញ្ញាណ ឬសមាជិកភាពរបស់ខ្លួនផ្ទាល់ ស្របតាមទំនៀមទម្លាប់ និងប្រពៃណីរបស់ពួកគេ។ ការនេះមិនធ្វើឲ្យបុគ្គលជនជាតិដើម បាត់បង់សិទ្ធិក្នុងការទទួលបានសញ្ជាតិពីរដ្ឋ ដែលខ្លួនរស់នៅឡើយ។

២/ជនជាតិដើម មានសិទ្ធិក្នុងការកំណត់រចនាសម្ពន្ធ និងជ្រើសរើសសមាជិកភាពនៃស្ថាប័នរបស់ខ្លួន ស្របតាមនិតិវិធីរបស់ខ្លួនផ្ទាល់។

*មាត្រា៣៤*

ជនជាតិដើម មានសិទ្ធិក្នុងការលើកកំពស់ បង្កើត និងរក្សារចនាសម្ព័ន្ធទំនៀមទំលាប់ សាសនា ប្រពៃណី និងនិតិវិធីប្រតិបត្តិជាពិសេស របស់ពួកគេ ហើយក្នុងករណីដែលមានប្រព័ន្ធវិនិច្ឆ័យក្តី ឬការវិនិច្ឆ័យក្តីតាមទំនៀមទំលាប់ត្រូវប្រកបតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

*មាត្រា ៣៥*

ជនជាតិដើម មានសិទ្ធិកំណត់ការទទួលខុសត្រូវ របស់បុគ្គលិកគ្រប់រូបក្នុងសហគមន៍របស់ពួកគេ។

*មាត្រា ៣៦*

១/ជនជាតិដើម ជាពិសេសជនជាតិទាំងឡាយ ដែលត្រូវបានបែងចែកដោយព្រំដែនអន្តរជាតិ មានសិទ្ធិរក្សា និងបង្កើតទំនាក់ទំនងកិច្ចប្រាស្រ័យ គ្នា និងកិច្ចសហការគ្នា រួមទាំងសកម្មភាពនានា ក្នុងគោលបំណងខាងជំនឿសាសនា វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ជាមួយសមាជិក ផ្ទាល់របស់ពួកគេ ក៏ដូចជាមួយអ្នកដ៏ទៃទៀត ដែលនៅក្រៅព្រំដែន។

២/រដ្ឋទាំងឡាយ ដោយមានកិច្ចពិគ្រោះយោបល់និងកិច្ចសហការជាមួយជនជាតិដើម ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីសម្របសម្រួលដល់ការប្រើប្រាស់ និងធានាដល់ការអនុវត្តសិទ្ធិទាំងនេះ។

*មាត្រា ៣៧*

១/ជនជាតិដើម មានសិទ្ធិចំពោះការទទួលស្គាល់ ការគោរពប្រតិបត្តិ និងការអនុវត្តសន្ធិសញ្ញា កិច្ចព្រមព្រៀម និងការសម្របសម្រួលក្នុងន័យស្ថាបនាដទៃទៀត ដែលបានសម្រេចជាមួយរដ្ឋ ឬជាមួយអ្នកស្នងបន្ត ព្រមទាំងមានសិទ្ធិឲ្យរដ្ឋផ្តល់កិត្តិយស និងគោរពចំពោះសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែង ក្នុងន័យស្ថាបនាទាំងនោះ។

២/គ្មានបញ្ញត្តិណាមួយ ក្នុងសេចក្តីប្រកាសនេះ អាចត្រូវបានធ្វើការបកស្រាយ ដើម្បីកាត់បន្ថយ ឬបំបាត់សិទ្ធិរបស់ជនជាតិដើម ដែលមានក្នុងសន្ធិសញ្ញា កិច្ចព្រមព្រៀង និងកិច្ចចាត់ចែងក្នុងន័យស្ថាបនាដទៃទៀតឡើយ។

*មាត្រា ៣៨*

រដ្ឋទាំងឡាយ ដោយមានការពិគ្រោះយោបល់ និងសហការជាមួយជនជាតិដើម ត្រូវចាត់វិធានការសមស្រប រួមទាំងវិធានការតាមផ្លូវច្បាប់ ដើម្បីសម្រេចគោលដៅនៃសេចក្តីប្រកាសនេះ។

*មាត្រា ៣៩*

ជនជាតិដើម មានសិទ្ធិក្នុងការទទួលជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ពីរដ្ឋ និងតាមរយៈកិច្ចសហការអន្តរជាតិ ដើម្បីទទួលបាននូវសិទ្ធិ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ។

*មាត្រា ៤០*

ជនជាតិដើម មានសិទ្ធិទទួលបាននូវសេចក្តីសំរេចដោយឆាប់រហ័ស តាមរយៈនិតិវិធីត្រឹមត្រូវនិងយុត្តិធម៌ ចំពោះដំណោះស្រាយលើជម្លោះ និងវិវាទជាមួយរដ្ឋ ឬភាគីផ្សេងទៀត ក៏ដូចជាវិធីដោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះរាល់ការរំលោភសិទ្ធិបុគ្គលនិងសិទ្ធិសមូហភាពរបស់ពួកគេ។ សេចក្តីប្រកាសនេះ ត្រូវពិចារណាយ៉ាងត្រឹមត្រូវ អំពីប្រពៃណី ទំនៀមទម្លាប់ វិធាន និងប្រព័ន្ធច្បាប់របស់ជនជាតិដើមពាក់ព័ន្ធ និងសិទ្ធិមនុស្សអន្តរជាតិនានា។

*មាត្រា ៤១*

អង្គការនិងទីភ្នាក់ងារឯកទេសនៃប្រព័ន្ធអង្គការសហប្រជាជាតិ និងអង្គការអន្តររដ្ឋាភិបាលនានា ត្រូវរួមចំណែកជំរុញឲ្យមានការធ្វើឲ្យសំរេចពេញលេញនូវសេចក្តីប្រកាសនេះ តាមរយៈការគៀងគរនិងកិច្ចសហប្រតិបត្តិការ ខាងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស។ ត្រូវបង្កើតឲ្យមាន វិធីនិងមធ្យោបាយ ដែលធានាឲ្យមានការចូលរួមពីសំណាក់ជនជាតិដើម ក្នុងបញ្ហាទាំងឡាយ ដែលប៉ះពាល់ដល់ពួកគេ។

*មាត្រា ៤២*

អង្គការសហប្រជាជាតិ ស្ថាប័ននានារបស់ខ្លួន រួមមានវេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើម និងទីភ្នាក់ងារឯកទេសនានា រួមទាំងនៅថ្នាក់ជាតិ ហើយរដ្ឋត្រូវលើកកំពស់ការគោរព និងការអនុវត្តទាំងស្រុងនូវបទបញ្ញត្តិនៃសេចក្តីប្រកាសនេះ និងតាមដានលើប្រសិទ្ធិភាពនៃសេចក្តីប្រកាសនេះ។

*មាត្រា៤៣*

សិទ្ធិទាំងឡាយ ដែលបានទទួលស្គាល់ក្នុងសេចក្តីប្រកាសនេះ បង្កើតបានជាបទដ្ឋានអប្បបរមា សម្រាប់ការរស់រានមានជីវិត ភាពថ្លៃថ្នូរ និងសុខុមាលភាពរបស់ជនជាតិដើមលើពិភពលោក។

*មាត្រា៤៤*

សិទ្ធិ និងសេរីភាពទាំងអស់ ដែលបានទទួលស្គាល់ក្នុងសេចក្តីប្រកាសនេះ ត្រូវបានធានាការពារដោយស្មើគ្នា ចំពោះជនជាតិដើម ទាំងបុរសនិងស្ត្រី។

*មាត្រា ៤៥*

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្តីប្រកាសនេះ អាចត្រូវបានធ្វើការបកស្រាយ ដើម្បីកាត់បន្ថយ ឬបំបាត់សិទ្ធិទាំងឡាយ ដែលជនជាតិដើមមាននាបច្ចុប្បន្ន ឬអាចមានក្នុងអនាគតឡើយ។

*មាត្រា ៤៦*

១/គ្មានបទបញ្ញត្តិណាមួយ ក្នុងសេចក្តីប្រកាសនេះត្រូវបានធ្វើការបកស្រាយ ដោយមិនច្បាស់លាស់ដោយរដ្ឋ ឬប្រជាពលរដ្ឋ ឬក្រុមណាមួយ ឬបុគ្គលណាម្នាក់ នូវសិទ្ធិណាមួយ ដើម្បីចូលរួមក្នុងសកម្មភាពនានា ឬដើម្បីប្រព្រឹត្តអំពើណាមួយ ផ្ទុយនឹងធម្មនុញ្ញសហប្រជាជាតិ ឬដើម្បីធ្វើការបកស្រាយថាជាការផ្តល់សិទ្ធិអំណាច ឬលើកទឹកចិត្តឲ្យមានទង្វើណាមួយ ដែលនាំឲ្យមានការបែងចែក ឬធ្វើឲ្យអន់ថយទាំងអស់ ឬមួយផ្នែក នៃបូរណភាពដែនដី ឬឯកភាពនយោបាយ នៃរដ្ឋអធិបតេយ្យនិងឯករាជ្យឡើយ។

២/ក្នុងការប្រើប្រាស់សិទ្ធិទាំងឡាយ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់មនុស្សទាំងអស់គ្នា ត្រូវតែបាទទួលការគោរព។ ការប្រើប្រាស់សិទ្ធិទាំងឡាយដែលមានចែងក្នុងសេចក្តីប្រកាសនេះ

អាចត្រូវដាក់ឲ្យស្ថិតក្នុងលក្ខខណ្ឌនៃការកំហិតព្រំដែន ដែលមានកំណត់តាមច្បាប់តែប៉ុណ្ណោះ និងដែលត្រូវស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ ការកំណត់លក្ខខ័ណ្ឌបែបនេះ ត្រូវធ្វើឡើងដោយគ្មានការរើសអើង ហើយដែលចាំបាច់បំផុតដើម្បីធានាការទទួលស្គាល់ និងការគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិ និងសេរីភាពអ្នកដទៃ ហើយឆ្លើយតបនឹងយុត្តិធម៌ ព្រមទាំងលក្ខខ័ណ្ឌបន្ទាន់បំផុត នៃសង្គមប្រជាធិបតេយ្យ។

៣/ការបកស្រាយនូវបទបញ្ញត្តិដែលមានចែងក្នុងសេចក្តីប្រកាសនេះ ត្រូវស្របតាមគោលការណ៍ យុត្តិធម៌ ប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស សមភាព ភាពគ្មានការរើសអើង អភិបាលកិច្ចល្អ និងសុឆន្ទៈ៕

**(ចប់)**